# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.គ លេខ ១០.០១៥/០៩ គ.ជ.ប.អគ្គ/ពស**

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៩

## គណបក្សនយោបាយចំនួន ០៥ និងអង្គការចំនួន ០៤ ចូលរួមសង្កេតការណ៍

គិតត្រឹមថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ មានគណបក្សនយោបាយចំនួន ០៥ និងអង្គការចំនួន ០៤ បានដាក់តំណាង និងអ្នកសង្កេតការណ៍សរុបចំនួន **៣.៦៩៥**នាក់ ចូលរួមសង្កេតមើលដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០០៩ ។

គណបក្សនយោបាយទាំង ០៥ ដែលបានដាក់តំណាងចូលរួមសង្កេតការណ៍សរុបចំនួន **៣.៥៦៣** នាក់ ក្នុងនោះរួមមាន៖

១- គណបក្ស ប្រជាជនកម្ពុជា មានតំណាងសរុបចំនួន ២.២៨៣នាក់ ពេញសិទ្ធិចំនួន ១.២២៥នាក់ និងបម្រុងចំនួន ១.០៥៨នាក់ ។

២- គណបក្ស សម រង្ស៊ី មានតំណាងសរុបចំនួន ១.០៤២នាក់ ពេញសិទ្ធិចំនួន ៦០៩នាក់ និងបម្រុងចំនួន ៤៣៣នាក់ ។

៣- គណបក្ស ជាតិនិយម មានតំណាងសរុបចំនួន ២២នាក់ ពេញសិទ្ធិចំនួន ១១ នាក់ និងបម្រុងចំនួន ១១នាក់ ។

៤- គណបក្ស ហ៊ុន ស៊ិន ប៊ិច មានតំណាងសរុបចំនួន ២០៣នាក់ ពេញសិទ្ធិចំនួន ១១៤នាក់ និងបម្រុងចំនួន ៨៩នាក់ ។

៥- គណបក្ស សិទ្ធិមនុស្ស មានតំណាងសរុបចំនួន ១៣នាក់ ពេញសិទ្ធិចំនួន ០៧នាក់ និងបម្រុងចំនួន ៦នាក់ ។

ចំពោះអង្គការដែលបានដាក់ពាក្យចូលរួមសង្កេតការណ៍មានចំនួន ០៤ គឺ ៖

- អង្គការគ្រួសារអភិវឌ្ឍន៍កសិកម្មមានអ្នកសង្កេតការណ៍ចំនួន ៣៦ នាក់ ក្នុងនោះចល័តចំនួន ០២នាក់ ត្រូវបាន គ.ជ.ប អនុញ្ញាត ។
- អង្គការចំនួន ០៣ ទៀតគឺ អង្គការខុមហ្វ្រែល មានអ្នកសង្កេតការណ៍ចំនួន ២៦នាក់ អង្គការលើកស្ទួយសុខមាលភាពជនក្រីក្រ មានចំនួន ១៤នាក់ ក្នុងនោះចល័តចំនួន ០២នាក់ និងសមាគមស្ត្រីសម្រាប់អភិវឌ្ឍន៍សិទ្ធិមនុស្ស ឧស្សាហកម្ម កសិកម្ម មានចំនួន ១៦នាក់ ក្នុងនោះចល័តចំនួន ០២នាក់ គ.ជ.ប កំពុងពិនិត្យលើពាក្យសុំ ។ GN ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងផ្នែកព័ត៌មានសាធារណៈ: ទូរស័ព្ទលេខ 012 855 018 & Fax 023 214 374 E-mail : necinfo@forum.org.kh Website: www.necelect.org.kh